**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន សាន់ ស៊ូ ហ្គាម៉ិន ខូអិលធីឌី**

# កិច្ចព្រមព្រៀង

## ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល២៣ថ្ងៃ

ថ្ងៃព្រហស្បតិ៍ ១២រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹង ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤ វេលាម៉ោង ១៤:០០នាទីរសៀល មានកិច្ចប្រជុំមួយនៅរោងចក្រ សាន់ ស៊ូ ហ្គាម៉ិន ខូអិលធីឌី មានអាសយដ្ឋានស្ថិតនៅភូមិ កប្បាស ឃុំខ្វិតធំ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ដោយមានលោក HUANG HUNG LIN ជានាយកក្រុមហ៊ុន បានបើកកិច្ចប្រជុំមួយជាមួយ លោក ធឹម ថា ជាប្រធានសហជីព និង បងប្អូនដែលជាប្រតិភូបុគ្គលិក ចំនួន ៣០ រូបផ្សេងទៀត ដែលតំណាងអោយកម្មករ កម្មការិនី សរុប ២៨០៤ នាក់។

ជាកិច្ចចាប់ផ្តើមលោក HUANG HUNG LIN ជាប្រធានអង្គប្រជុំ បានមានមតិស្វាគមន៍ដល់បងប្អូនប្រតិភូមបុគ្គលិក ទាំងអស់ដែលបានចូលរួម និងបានបើកកិច្ចពិភាក្សាអំពីការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតនៅផ្នែកព្រីន ចំនួន៦៨នាក់ សម្រាប់រយៈពេល ២៣ថ្ងៃដោយគឺចាប់ពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៤ ដល់ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៤ ដោយសារស្ថានភាពបញ្ជាទិញរបស់អតិថិជនមានការធ្លាក់ចុះយ៉ាងខ្លាំង។

ក្រោយការពិភាក្សាគ្នា រវាងភាគីតំណាងក្រុមហ៊ុន និង ប្រតិភូបុគ្គលិក រួចមក ភាគីទាំងពីរបានឯកភាពផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតម្នាក់ៗចំនួន ៣០ដុល្លារ រក្សាប្រាក់រង្វាន់ទៀងទាត់(ព្រីន)ព្រមទាំងប្រាក់ធ្វើដំណើរ ក្នុងកំឡុងពេលនៃការព្យួរនេះនិង បើកជូនបងប្អូនកម្មករ និយោជិតនៅ ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៤។

កិច្ចពិភាក្សាបានបញ្ចប់ នៅវេលាម៉ោង ១៥:០០នាទីរសៀលនៅថ្ងៃខែឆ្នាំដដែល ក្រោមស្មារតីយោគយល់គ្នា និង ទទួលយកនូវស្មារតីនៃកិច្ចព្រមព្រៀងនេះ។

ថ្ងៃព្រហស្បតិ៍ ១២រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ព្រៃឈរ ថ្ងៃទី០១ ខែ សីហា ឆ្នាំ២០២៤

**ភាគីទាំងពីរបានឯកភាព និង ផ្តិតមេដៃទុកជាភស្តុតាង**

**ប្រតិភូបុគ្គលិក** **តំណាងក្រុមហ៊ុន**

ធឹម ថា ជា គឹមឡាត់ វ៉េង ណារ៉ា

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន សាន់ ស៊ូ ហ្គាម៉ិន SUN HSU GARMENT Co., Ltd KINGDOM OF CAMBODIA

**លោក** HUANG HUNG LIN

| | | | |
|---|---|---|---|
| ទឹម ម៉េងអ៊ី | ជួន សេងហួរ | ផៃ ស្រីនាង | ជុះ ឃុនស្រីពៅ |
| ម៉ម ប៉ូឡូ | ស៊ុន សុខនៃ | ម៉េស ស្រីមុំ | លី ចាន់ថា |
| ធឹម ធី | ឃឹម ណាក់ | ភោគ ថាវី | សាំ ចាន់នី |
| ធន ណាំគ្រឿន | គូ ចំរើន | ចាន់ ដាលីន | គីម ធីម |
| ជុំ សិលា | ប៉ុល សៅ | ថេន ដានី | ថៃ សុផល |
| ថែម ប៉ា | ជឿន ស្រីល័ក្ខ | មួន ណារ៉េន | យ៉ាន់ ស្មើ |
| ស៊ឹម ស្រីម៉ៅ | ឃឹម ធី | ជុំ ចន្ទី | ម៉ន ចាន់បូផា |

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
សាន់ ស៊ូ ហ្គាម៉ិន
SUN HSU GARMENT
Co.,Ltd
KINGDOM OF CAMBODIA